# RECOMMENDATIONS

## OF REGIONAL CONFERENCE ON SOCIAL IMPACT OF CLIMATE CHANGE ON WOMEN AND CHILDREN IN ASEAN

asean

one vision
one identity
one community

# RECOMMENDATIONS

## OF REGIONAL CONFERENCE ON

## SOCIAL IMPACT OF CLIMATE CHANGE

## ON WOMEN AND CHILDREN IN ASEAN

The ASEAN Secretariat
Jakarta

The Association of Southeast Asian Nations (ASEAN) was established on 8 August 1967. The Member States of the Association are Brunei Darussalam, Cambodia, Indonesia, Lao PDR, Malaysia, Myanmar, Philippines, Singapore, Thailand and Viet Nam.
The ASEAN Secretariat is based in Jakarta, Indonesia.

For inquiries, contact:
The ASEAN Secretariat
Community Relations Division (CRD)
70A Jalan Sisingamangaraja
Jakarta 12110, Indonesia
Phone: (62 21) 724-3372, 726-2991
Fax: (62 21) 739-8234, 724-3504
E-mail: public@asean.org

Catalogue-in-Publication Data

Recommendations of Regional Conference on Social Impact of Climate Change on Women and Children in ASEAN
Jakarta: ASEAN Secretariat, August 2019

304.2059
1. ASEAN – Environment – Climate change
2. Women Rights – Children Rights

ISBN 978-602-5798-39-9

ASEAN: A Community of Opportunities for All

The text of this publication may be freely quoted or reprinted, provided proper acknowledgement is given and a copy containing the reprinted material is sent to the Community Relations Division (CRD) of the ASEAN Secretariat, Jakarta

General information on ASEAN appears online at the ASEAN Website: www.asean.org

Copyright Association of Southeast Asian Nations (ASEAN) 2019.
All rights reserved.

# TABLE OF CONTENTS

PREFACE ........ v

INTRODUCTION ........ 1

RECOMMENDATIONS ........ 3

I. POLICY FRAMEWORK AND IMPLEMENTATION ........ 3

II. PREVENTION, EDUCATION AND AWARENESS RAISING ........ 5

III. RESOURCES MOBILISATION AND GOVERNANCE ........ 6

IV. SERVICE PROVISION AND SUPPORTS ........ 7

# PREFACE

The ASEAN region remains one of the most vulnerable regions in the world to climate change. The disasters and impact arising from climate change disproportionately and adversely affect the poor and low-income populace. Climate change not only hampers development but significantly affects the rights of women and children specially their livelihood, food security, education and health. This has even led to the exacerbation of violence against women and children, among the most vulnerable groups.

In March 25 to 26, 2015, a *"Regional Conference on Social Impact of Climate Change on Women and Children in ASEAN"* was initiated and convened in Phnom Penh by Cambodia under the framework of the ASEAN Commission on the Promotion and Protection of the Rights of Women and Children (ACWC) Work Plan 2012-2016. The Conference funded by the Ministry of Social Affairs, Veterans and Youth Rehabilitation (MOSVY) of the Royal Government of Cambodia, UNICEF and UN Women aimed to understand the social impact of climate change on women and children in ASEAN to prepare recommendations.

The resulting recommendations which sought actions to address the social impact of climate change on women and children in ASEAN were unanimously agreed upon by all AMSs.

In order to disseminate the recommendations of the Conference, ACWC is publishing this booklet of recommendations to be used by all relevant stakeholders,

policy makers, programme practitioners, community workers, women and children in ASEAN.

My sincere thanks to all ACWC Representatives and to everyone who contributed to developing the recommendations, and specially the UNICEF Cambodia Office for supporting the publication of this booklet.

*Theng Chhorvirith*
*Cambodia's Representative to ACWC*
*for Children's Rights*

# INTRODUCTION

ASEAN Member States (AMS) remain vulnerable to disasters which disproportionately affect the poor populace. While pollution and resource degradation are already serious problems, the region is also among the most vulnerable to climate change. Thus, it needs to find solutions to adapt and to build a resilient ASEAN.

The Fifth Assessment Report (AR5I) of International Panel on Climate Change (IPCC) reveals that in spite of current actions in combating climate change through mitigation, the global community still faces an increased amount of anthropogenic generated greenhouse gas emissions as the leading cause of climate change. IPCC also predicted that temperature would be rising from 1-2.5°C generating adverse effects to development, particularly on livelihood, food security, education and health.

The ASEAN region has long coastlines with heavy concentration of population. High dependence on fishing is evident while other parts are reliant on agriculture as well as extraction of forest and other natural resources. Though a source of economic strength, these characteristics contribute to the area's vulnerability to the impact of climate change. Climate hazards such as increase in temperature, erratic rainfall patterns, and extreme climatic events like strong typhoons and severe droughts have adversely affected the ecosystem. This render vulnerable livelihood and other aspects of people's lives.

Widespread poverty in the region aggravates vulnerability to impact of climate change. The exposure to risk is especially magnified among the low-income segment of societies where mitigation is found to be less sensitive to the specific needs of women and children.

In realizing the overarching goals of the ASEAN Community 2025, the ASEAN Social Cultural Community (ASCC) pursues a more inclusive community within the broader context of an environment that is adaptive to the challenges of climate change and sustainability. The aim is for a community whose people participates in the pursuit of and enjoys the benefit of sustainable development. Such is also in keeping with the inclusive growth agenda of the ASEAN Economic Community (AEC) that stresses equal access and opportunity for all and where human rights are duly promoted and protected. With this goes the emphasis on addressing the additional concerns of all peoples of ASEAN on matters related to social protection, gender equality, poverty eradication, health, decent work, education, and information.

Addressing the challenges of climate change on women and children requires streamlined policies and coordinated efforts. The vital documents include the following: United Nations Framework Convention on Climate Change (UNFCCC), Convention on the Elimination of All Forms of Discrimination Against Women (CEDAW), United Nations Convention on the Rights of the Child (UNCRC), and ASEAN Agreement on the Disaster Management and Emergency Response (AADMER). National frameworks on combating climate change are likewise necessary for getting the right assistance, especially for women and children who are most vulnerable to the impact.

*(With reference to the outcomes of the Third UN World Conference Sendai Framework for Disaster Risk Reduction 2015-2030 held on 14-18 March 2015 in Sendai, Miyagi, Japan, and the Regional Conference on Social Impact of Climate Change on Women and Children in ASEAN held on 25-26 March 2015 in Phnom Penh, Cambodia and attended by ACWC representatives from nine AMSs, UN agencies, Civil Society Organizations (CSOs) and experts on climate change)* .

The Regional Conference unanimously agreed on the recommendations below for all ASEAN Member States to take effective measures in tackling climate change and its impact on women and children in ASEAN.

## RECOMMENDATIONS

## I. POLICY FRAMEWORK AND IMPLEMENTATION

1. To mainstream climate change and its impact on women and children into national, sub-national and sectoral planning including its implementation in line with national and international frameworks.

2. To promote women and children's active and meaningful participation at all levels (local, national, regional and international) in decision-making processes and implementation of policies, plans, and programmes on climate change.

3. To ensure gender and child-sensitive approach[1] in climate change adaptation and mitigation including disaster risk reduction and management through collaborative work among stakeholders.

4. To promote the understanding of social impact of climate change on women and children in the ASEAN Member States and empower the same on climate change adaptation/mitigation through the conduct of social impact analyses and vulnerability and adaptation assessments.

5. To develop or strengthen development plans at all levels based on gender and child-sensitive social impact analyses and vulnerability and adaptation assessments.

6. To strengthen the collaboration between and among ASEAN Member States and relevant UN Agencies and Development Partners to implement policies and programmes on climate change affecting women and children.

7. To develop Regional Guidelines for Implementing the Service Provision and Support to address the specific needs of women and children.

8. To include the impact of climate change on women and children in the next ASEAN Joint Statement on Climate Change which is expected to be adopted by ASEAN Leaders in 27th ASEAN Summit.

[1] UNICEF Climate Change and Children Joint Policy

## II. PREVENTION, EDUCATION AND AWARENESS RAISING

9. To encourage stakeholders to actively use the social media to engage the public in educating and raising people's awareness about climate change issues and disasters and how it adversely affects women and children including Persons with Disability/ies (PWDs), and the elderly.

10. To develop a more effective alert and warning strategies/system to reach all affected people in remote areas, especially those who do not have access to information.

11. To integrate climatic issues in the curriculum of schools from kindergarten to university with particular focus on the implementation of Eco-school programmes and Safe Schools Initiative.

12. To promote capacity building on social impact of climate change, adaptation/mitigation, and risk management at the grass-root level particularly, for women and children.

13. To increase the active and meaningful participation of local communities including women and children in the planning and drafting of programmes that mitigate the impact of climate change with the end of forging cooperation and accountability of all sectors in disaster risk reduction management.

14. To promote the sharing of information, experiences, and best practices between and among the ASEAN Member States.

## III. RESOURCES MOBILISATION AND GOVERNANCE

15. To allocate specific budget/funds for women and children to respond to the social impact of climate change and establish financial mechanisms of resource mobilisation.

16. To establish or appoint one specific agency to manage, mobilise and allocate resources supporting the operations at the sub-national/local level.

17. To strengthen ASEAN Cooperation in human and institutional capacity building for fund management about the social impact of climate change.

18. To encourage ASEAN to generate a comprehensive regional social impact on climate change data that is sex-disaggregated and which include, among other variables, age, number of victims, location, and disaster situation.

19. To encourage donors to increase funding for work that addresses the issues of social impact of climate change on women and children, including the promotion of their adaptation, agency/resilience to climate change.

## IV. SERVICE PROVISION AND SUPPORTS

20. To provide public facilities, e.g. clean water and sanitary markets, schools, adequate shelters, healthcare stations, government offices, etc., for those affected by climate change.

21. To promote access and control of livelihood, ownership of household assets, adaptation skills trainings, finance and technology for those affected by climate change particularly for women.

# អនុសាសន៍

## ស្តីពី
## ផលប៉ះពាល់សង្គម
## នៃការប្រែប្រួលអាកាសធាតុ មកលើស្ត្រី
## និងកុមារ ក្នុងតំបន់អាស៊ាន

asean

ចក្ខុវិស័យមួយ
អត្តសញ្ញាណមួយ
សហគមន៍តែមួយ

# អនុសាសន៍

## ស្តីពី
## ផលប៉ះពាល់សង្គម
## នៃការប្រែប្រួលអាកាសធាតុ មកលើស្ត្រី
## និងកុមារក្នុងតំបន់អាស៊ាន

លេខាធិការដ្ឋានអាស៊ាន
ហ្សាកាតា

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)បានបង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧។ រដ្ឋជាសមាជិកអាស៊ានរួមមាន៖ ប្រ៊ុយណេដារូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សឹង្ហបុរី ថៃ និងវៀតណាម។ លេខាធិការដ្ឋានអាស៊ានមានទីស្នាក់ការនៅទីក្រុងហ្សាកាតា, ប្រទេសឥណ្ឌូនេស៊ី។

សម្រាប់ព័ត៌មានទំនាក់ទំនង៖
លេខាធិការដ្ឋានអាស៊ាន
ផ្នែកទំនាក់ទំនងសហគមន៍
៧0A ចាឡាន ស៊ីស៊ីនហ្គាម៉ាន់ហ្គារ៉ាចា, ហ្សាកាតា ១២១១០
ឥណ្ឌូនេស៊ី

| | | |
|---|---|---|
| ទូរស័ព្ទ | : | (៦២ ២១)៧២៤-៣៣៧២, ៧២៦-២៩៩១ |
| ទូរសារ | : | (៦២ ២១)៧៣៩-៨២៣៤, ៧២៤-៣៥០៤ |
| អ៊ីមែល | : | public@asean.org |


បញ្ជីក្នុងការបោះពុម្ពផ្សាយទិន្នន័យ
អនុសាសន៍ ស្ដីពីផលប៉ះពាល់សង្គម នៃការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារ ក្នុងតំបន់អាស៊ាន
ហ្សាកាតា, លេខាធិការដ្ឋានអាស៊ាន, សីហា, ២០១៩

៣០៤.២០៥៩
១. អាស៊ាន – បរិស្ថាន – ការប្រែប្រួលអាកាសធាតុ
២. សិទ្ធិស្ត្រី – សិទ្ធិកុមារ

ISBN 978-602-5798-39-9

9 786025 798399

អាស៊ាន: សហគមន៍មួយឱកាសសម្រាប់ទាំងអស់គ្នា

អត្ថបទបោះពុម្ពផ្សាយនេះអាចដកស្រង់ដោយសេរី ឬបោះពុម្ពឡើងវិញបាន ដោយមានការទទួលស្គាល់និងមានការអនុញ្ញាតត្រឹមត្រូវ ហើយឯកសារច្បាប់ចម្លងដែលបានបោះពុម្ពឡើងវិញរួចត្រូវបញ្ជូនទៅផ្នែកទំនាក់ទំនងសហគមន៍ (CRD) របស់លេខាធិការដ្ឋានអាស៊ាន, ហ្សាកាតា។

ព័ត៌មានទូទៅស្តីពីអាស៊ានត្រូវបង្ហាញនៅលើបណ្តាញអាស៊ាន
Website: www.asean.org

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឆ្នាំ២០១៩
រក្សារសិទ្ធគ្រប់យ៉ាង

# មាតិកា


អារម្ភកថា ........................................ vii

សេចក្តីផ្តើម ........................................ ១

អនុសាសន៍ ........................................ ៤

I. ក្របខណ្ឌគោលនយោបាយ និងការអនុវត្ត .......... ៤

II. ការការពារ, ការអប់រំ និងការផ្សព្វផ្សាយ .......... ៦

III. ការគ្រៀគរធនធាន និងអភិបាលកិច្ច .......... ៧

IV. ការផ្តល់សេវាកម្ម និងការគាំទ្រ .......... ៨

## អារម្ភកថា

អាស៊ានជាតំបន់ដែលងាយរងគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុខ្លាំងជាងគេបំផុតក្នុងចំណោមតំបន់នានាទាំងអស់លើពិភពលោក។ គ្រោះមហន្តរាយធម្មជាតិ និងការកើនឡើងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុបណ្តាលឲ្យមានវិសមាមាត្រ និងប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនក្រីក្រដែលមានចំណូលទាប។ ការប្រែប្រួលអាកាសធាតុមិនត្រឹមតែរារាំងដល់ការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិស្ត្រី និងកុមារជាពិសេសប៉ះពាល់ដល់ជីវភាពរស់នៅដូចជា៖ សុវត្ថិភាពស្បៀង, ការសិក្សាអប់រំ និងសុខភាព។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក៏បង្កឲ្យកើតមានបញ្ហាធ្ងន់ធ្ងរជាច្រើនទៀតដូចជាគឺអំពើហិង្សាលើស្ត្រី និងកុមារ ពិសេសក្នុងចំណោមក្រុមជនដែលងាយរងគ្រោះ។

នៅថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០១៥ *“សន្និសីទថ្នាក់តំបន់ស្តីពីផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុមកលើស្ត្រីនិងកុមារក្នុងតំបន់អាស៊ាន”*បានផ្តួចផ្តើមនិងអនុវត្តន៍ដោយប្រទេសកម្ពុជា ក្រោមក្របខណ្ឌផែនការសកម្មភាពរបស់គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ឆ្នាំ២០១២-២០១៦។ សន្និសីទថ្នាក់តំបន់នេះបានប្រព្រឹត្តិទៅដោយមានការគាំទ្រថវិកាពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) នៃរាជរដ្ឋាភិបាលកម្ពុជា, អង្គការយូនីសេហ្វ (UNICEF) និងអង្គការ UN Women ប្រចាំនៅកម្ពុជា ក្នុងគោលបំណងដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារនៅតំបន់អាស៊ាន និងរៀបចំអនុសាសន៍ដើម្បីដោះស្រាយ។

ជាលទ្ធផល អនុសាសន៍ ដើម្បីចាត់វិធានការដោះស្រាយបញ្ហាផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន បានអនុម័តជាឯកច្ឆ័ន្ទដោយរដ្ឋសមាជិកអាស៊ានទាំងអស់។

ដើម្បីចែករំលែកនិងផ្សព្វផ្សាយអនុសាសន៍នេះឲ្យបានទូលាយ គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) បានបោះពុម្ពសៀវភៅអនុសាសន៍នេះឡើងដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធនានាដូចជា៖ អ្នករៀបចំគោលនយោបាយ, អ្នកអនុវត្តកម្មវិធី, អ្នកធ្វើការតាមសហគមន៍ និងស្ត្រីនិងកុមារក្នុងតំបន់អាស៊ាន។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិកតំណាងគណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) ទាំងអស់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក-លោកស្រីដែលបានចូលរួមក្នុងដំណើរការរៀបចំសៀវភៅអនុសាសន៍នេះឲ្យកើតចេញជារូបរាងឡើង ហើយក៏សូមថ្លែងអំណរគុណជាពិសេសដល់អង្គការ UNICEF ប្រចាំកម្ពុជាចំពោះការគាំទ្រសម្រាប់ការបោះពុម្ពសៀវភៅអនុសាសន៍នេះ។

*ថេង ឆវិរិទ្ធ*
*តំណាង គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់*
*និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)*
*ផ្នែកសិទ្ធិកុមារកម្ពុជា*

# សេចក្តីផ្តើម

រដ្ឋនៃសមាជិកអាស៊ានទាំងអស់ បាននិងកំពុងប្រឈមទៅនឹងគ្រោះមហន្តរាយធម្មជាតិ ដែលបណ្តាលឲ្យទទួលរងការប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនក្រីក្រ។ ការកើនឡើងឧស្ម័នជាតិពុល និងការបាត់បង់ធនធានធម្មជាតិ គឺជាកត្តាបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរជាច្រើនដល់សង្គម។ ដោយឡែកតំបន់អាស៊ានមានភាពប្រឈមខ្លាំងបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ។ តំបន់នេះត្រូវចាត់វិធានការដោះស្រាយជាចាំបាច់ចំពោះការបន្សាំទៅនឹងការរស់នៅ និងការសម្របខ្លួនទៅក្នុងតំបន់អាស៊ាន ។

របាយការណ៍វាយតម្លៃលើកទី៥ របស់គណៈកម្មការអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានបង្ហាញឲ្យឃើញថា ទោះបីមានសកម្មភាពជាច្រើនបាននិងកំពុងទប់ស្កាត់ការប្រែប្រួលអាកាសធាតុក៏ដោយ ក៏សកលលោកទាំងមូលនៅតែប្រឈមនឹងការកើនឡើងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលជាកត្តាចម្បង បណ្តាលឲ្យមានការកើនឡើងនៃការប្រែប្រួលអាកាសធាតុ។ គណៈកម្មការអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) ក៏បានព្យាករណ៍ថា សីតុណ្ហភាពនឹងកើនកំដៅពី ១-២.៥ អង្សាសេ នាពេលខាងមុខ ហើយការប្រែប្រួលនេះ នឹងបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់ដំណើរការអភិវឌ្ឍ ពិសេសប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនដូចជា៖ សុវត្ថិភាពស្បៀង, ការសិក្សាអប់រំ និងសុខភាព។

តំបន់អាស៊ានមានឆ្នេរដ៏វែង និងមានចំនួនប្រជាជនជាច្រើនរស់នៅ។ ប្រជាជនភាគច្រើនរស់នៅពឹងផ្អែកលើផលនេសាទ ហើយប្រជាជនមួយចំនួនទៀតអាស្រ័យផលលើវិស័យកសិកម្ម ដូចជាការទាញយកពីអនុផលព្រៃឈើ

និងធនធានធម្មជាតិផ្សេងៗជាដើម។ ទោះបីប្រភពធនធានតំបន់អាស៊ានសម្បូរបែបក៏ដោយ ក៏កត្តាទាំងនេះបានបង្ករឲ្យមានភាពងាយរងគ្រោះខ្លាំងបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុបណ្តាលឲ្យមានការកើនឡើងសីតុណ្ហភាព ដែលបង្ករឲ្យមានលំនាំទឹកភ្លៀងខុសប្រក្រតី និងបង្ករឲ្យមានបាតុភូតធម្មជាតិដូចជា៖ ខ្យល់ព្យុះ, ទឹកជំនន់ និងភាពរាំងស្ងួត។ល។ ជាហេតុបង្ករឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅអេកូរជីវចម្រុះ ដែលជាកត្តាបណ្តាលឲ្យមានផលប៉ះពាល់ដល់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាជន។

ការរីករាលដាលនៃភាពក្រីក្រនៅក្នុងតំបន់ គឺជាកត្តាដ៏ធ្ងន់ធ្ងរមួយបន្ថែមទៀត កាន់តែបង្ករឲ្យមានភាពប្រឈមយ៉ាងខ្លាំងដល់ក្រុមជនងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។ ការប្រឈមនេះបណ្តាលឲ្យមានបញ្ហាកាន់តែច្រើនឡើងៗចំពោះអ្នកក្រដែលមានចំណូលទាប និងទទួលបានការគាំទ្រតិចតួចបំផុត ពិសេសចំពោះតម្រូវការចាំបាច់របស់ស្ត្រី និងកុមារ។

ដើម្បីសម្រេចបានគោលដៅរបស់សហគមន៍អាស៊ាននៅឆ្នាំ២០២៥ សហគមន៍វប្បធម៌សង្គមអាស៊ាន (ASCC) មានទស្សនៈរួម គឺសហគមន៍អាស៊ានខិតខំប្រឹងប្រែងឲ្យមានការដាក់បញ្ចូលបរិបទបរិស្ថានឲ្យបានទូលាយចំពោះការបន្សាំុនឹងភាពប្រឈមនៃការប្រែប្រួលអាកាសធាតុ និងប្រកបដោយនិរន្តរភាព។ គោលដៅរបស់សហគមន៍អាស៊ានគឺខិតខំដើម្បីឲ្យប្រជាជនមានការចូលរួមប្រឹងប្រែង និងរីករាយទទួលផលប្រយោជន៍ពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការងារទាំងអស់នេះបាននិងកំពុងរក្សាបាននូវរបៀបវារៈនៃការអភិវឌ្ឍសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលបានបញ្ជាក់ ពីសិទ្ធិទទួលបានស្មើភាពគ្នា និងឱកាសស្មើភាពគ្នា ហើយគ្រប់ៗគ្នាមានសិទ្ធិដែលត្រូវបានលើកកម្ពស់ និង

ទទួលបានការការពារ។ ជាមួយគ្នានេះ ការងារដែលចាំបាច់ត្រូវដោះស្រាយបន្តទៀត នូវបញ្ហាពាក់ព័ន្ធសម្រាប់ប្រជាជនអាស៊ាន គឺកិច្ចគាំពារសង្គម, សមភាពយេនឌ័រ, ការកាត់បន្ថយភាពក្រីក្រ, សុខភាព, ការងារសម្បរម្យ, ការសិក្សាអប់រំ និងការទទួលបានព័ត៌មានសមស្រប។

ការដោះស្រាយភាពប្រឈមនៃការប្រែប្រួលអាកាសធាតុលើស្ត្រីនិងកុមារតម្រូវឲ្យមានការអនុវត្តគោលនយោបាយ ការសម្របសម្រួល និងចាត់វិធានការត្រឹមត្រូវស្របតាមការអនុវត្តអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC), អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW), អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) និងកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងឲ្យគ្រោះមហន្តរាយនិងការឆ្លើយតបសង្គ្រោះបន្ទាន់ (AADMER) និងគោលនយោបាយផ្សេងៗទៀត ដើម្បីដោះស្រាយភាពប្រឈមទាំងអស់ឲ្យកាន់តែមានប្រសិទ្ធភាព។ លើសពីនេះ ក្របខណ្ឌជាតិស្តីពីការលុបបំបាត់ការប្រែប្រួលអាកាសធាតុក៏មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ជួយដល់ការស្វែងរកជំនួយសម្រាប់កម្មវិធីស្ត្រី និងកុមារដែលទទួលរងផលប៉ះពាល់នៃការប្រែប្រួល អាកាសអាធាតុ។

*(យោងតាមលទ្ធផល នៃអង្គសន្និសីទពិភពលោករបស់អង្គការសហប្រជាជាតិលើកទី៣ ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី១៤-១៨ ខែមីនា ឆ្នាំ២០១៥ នៅទីក្រុងសេនដាយមីយ៉ាហ្គិ ប្រទេសជប៉ុន និងសន្និសីទថ្នាក់តំបន់ស្តីពីផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ានដែលបានប្រព្រឹត្តិទៅកាលពីថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០១៥ នៅ*

*ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដែលមានតំណាងចូលរួមមកពី ៩ប្រទេសនៃរដ្ឋសមាជិកអាស៊ាន រួមទាំងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល និងអ្នកជំនាញស្ដីពីការប្រែប្រួលអាកាសធាតុមកពីប្រទេសនៃរដ្ឋសមាជិកអាស៊ានបានទទួលលទ្ធផលផ្លែផ្កាគួជាទីមោទនៈ)។*

សន្និសីទថ្នាក់តំបន់បានឯកភាពជាឯកច្ឆ័ន្ទលើអនុសាន៍ ដូចដែលបានពិព៌ណនាខាងក្រោម សម្រាប់រដ្ឋសមាជិកអាស៊ានចាត់វិធានការ ប្រកបដោយប្រសិទ្ធភាព ក្នុងការដោះស្រាយការប្រែប្រួលអាកាសអាតុ និងផលប៉ះពាល់នៃប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន៖

# អនុសាសន៍

## I. ក្របខណ្ឌគោលនយោបាយ និងការអនុវត្ត

១. បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងបញ្ហានានារបស់ស្ត្រី និងកុមារទៅក្នុងផែនការថ្នាក់ជាតិ ក្រោមជាតិ និងផែនការពហុវិស័យ និងមានការអនុវត្តត្រឹមត្រូវស្របតាមក្របខណ្ឌជាតិ និងអន្តរជាតិ។

២. លើកកម្ពស់ការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យរបស់ស្ត្រី និងកុមារគ្រប់កម្រិតទាំងអស់ (ថ្នាក់មូលដ្ឋាន, ថ្នាក់ជាតិ, ថ្នាក់តំបន់និងថ្នាក់អន្តរជាតិ) ក្នុងការចូលរួមដំណើរការសម្រេចចិត្ត, ការអនុវត្តគោលនយោបាយ, ការធ្វើផែនការ និងអនុវត្តកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ។

៣. ធានាថាការងារយេនឌ័រ និងវិធីសាស្ត្រកុមារ[១] ត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីការបន្ស៊ាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ រួមទាំងការកាត់បន្ថយគ្រោះមហន្តរាយ និងការគ្រប់គ្រងមហន្តរាយ តាមរយៈកិច្ចសហការជាមួយដៃគូរអ្នកពាក់ព័ន្ធ។

៤. លើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុលើស្ត្រី និងកុមារនៅក្នុងប្រទេសសមាជិកអាស៊ាន តាមរយៈការសិក្សាស្រាវជ្រាវ និងវិភាគលើផលប៉ះពាល់ និងភាពងាយរងគ្រោះ និងការវាយតម្លៃពីភាពបន្ស៊ាំ។

៥. រៀបចំ ឬពង្រឹងការអភិវឌ្ឍផែនការ គ្រប់កម្រិតទាំងអស់ ដោយផ្អែកលើយេនឌ័រ និងវិភាគផលប៉ះពាល់សង្គមលើស្ថានភាពកុមារ និងភាពងាយរងគ្រោះនិងការវាយតម្លៃពីភាពបន្ស៊ាំ។

៦. ពង្រឹងកិច្ចសហការ រវាងរដ្ឋសមាជិកអាស៊ាន ជាមួយភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍនក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុដែលប៉ះពាល់ដល់ស្ត្រី និងកុមារ។

---

[១] គោលនយោបាយរបស់អង្គយូនីសេហ្វ ស្តីពីការប្រែប្រួលអាកាសធាតុ

៧. រៀបចំគោលការណ៍ណែនាំ ថ្នាក់តំបន់សម្រាប់ការអនុវត្តលើការផ្តល់សេវាកម្ម និងកិច្ចគាំពារដោះស្រាយតម្រូវការចាំបាច់នានារបស់ស្ត្រី និងកុមារ។

៨. ដាក់បញ្ចូលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារទៅក្នុងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការប្រែប្រួលអាកាសធាតុដែលត្រូវអនុម័តដោយថ្នាក់ដឹកនាំអាស៊ាននាកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលលើកទី២៧ របស់អាស៊ាន។

## II. ការការពារ, ការអប់រំ និងការផ្សព្វផ្សាយ

៩. ជំរុញអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គមឲ្យមានការចូលរួមយ៉ាងសកម្មជាមួយរដ្ឋាភិបាល ដើម្បីអប់រំនិងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីបញ្ហាការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយជាពិសេសដល់ក្រុមយុវជន និងកុមារ។

១០. បង្កើតប្រព័ន្ធប្រកាសអាសន្ន និងប្រព័ន្ធការប្រុងប្រយ័ត្នឲ្យបានដល់ជនរងគ្រោះ និងជនងាយរងគ្រោះទាំងអស់ឲ្យទទួលបានព័ត៌មានគ្រប់គ្រាន់និងមានប្រសិទ្ធភាព (ឧ.ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល, ប្រជាពលរដ្ឋដែលមិនអាចទទួលបានព័ត៌មាន ។ល។)។

១១. ដាក់បញ្ចូល បញ្ហាការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីសិក្សាតាំងពីកម្រិតថ្នាក់មតេយ្យសិក្សា ដល់សាកលវិទ្យាល័យ និងលើកកម្ពស់ការអនុវត្តកម្មវិធីសាលាបរិស្ថានអេកូ និងផ្តួចផ្តើមឲ្យមានសាលាសុវត្ថិភាពគ្រប់កម្រិត។

១២. លើកកម្ពស់ការកសាងសមត្ថភាព ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៅថ្នាក់មូលដ្ឋាន ជាពិសេសសម្រាប់ស្ត្រី និងកុមារ។

១៣. បង្កើនការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យរបស់សហគមន៍មូលដ្ឋាន រួមទាំងស្ត្រី និងកុមារក្នុងដំណើរការរៀបចំផែនការ និងកម្មវិធីស្តីពីការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ លើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់វិស័យ ក្នុងការឆ្លើយតបតម្រូវការបន្ទាន់ទៅនឹងគ្រោះមហន្តរាយ។

១៤. លើកកម្ពស់ការចែករំលែកព័ត៌មាន បទពិសោធន៍ និងការអនុវត្តល្អរវាងរដ្ឋសមាជិកអាស៊ានទាំងអស់។

## III. ការកៀរគរធនធាន និងអភិបាលកិច្ច

១៥. បែងចែក ថវិកា/មូលនិធិជាក់លាក់សម្រាប់ស្ត្រី និងកុមារដើម្បីឆ្លើយតបផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុ និងបង្កើតឲ្យមានយន្តការនៃការគ្រប់គ្រងហិរញ្ញវត្ថុការកៀរគរធនធាន។

១៦. បង្កើត ឬតែងតាំងភ្នាក់ងារណាមួយ ដើម្បីគ្រប់គ្រង កៀរគរ និងបែងចែកធនធានសម្រាប់ការគាំទ្រដល់ប្រតិបត្តិការថ្នាក់ក្រោមជាតិ/មូលដ្ឋាន។

១៧. ពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន ទាំងធនធានមនុស្ស និងសមត្ថភាពស្ថាប័ន សម្រាប់ការគ្រប់គ្រងមូលនិធិពាក់ព័ន្ធទៅនឹងផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុ ។

១៨. ជំរុញលើកទឹកចិត្ត ស្ថាប័នអាស៊ាន ប្រមូលទិន្នន័យ ស្តីពីផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុ ឲ្យបានជាក់លាក់រួមទាំងបញ្ជាក់ពីទិន្នន័យ បែងចែកភេទ, ចំនួនជនរងគ្រោះ ទីតាំង និងស្ថានភាពគ្រោះមហន្តរាយជាដើម។

១៩. ជំរុញលើកទឹកចិត្ត ម្ចាស់ជំនួយ ឲ្យបង្កើនមូលនិធិសម្រាប់ការងារសំដៅជួយដោះស្រាយបញ្ហាផលប៉ះពាល់សង្គមនៃការប្រែប្រួលអាកាសធាតុលើស្ត្រី និងកុមារ។

## IV. ការផ្តល់សេវាកម្ម និងការគាំទ្រ

២០. ផ្តល់ទីកន្លែងសាធារណៈ ឧ. ទឹកស្អាត និងផ្សារដែលមានអនាម័យ, សាលារៀន, ទីជម្រកគ្រប់គ្រាន់, កន្លែងថែទាំសុខភាព, ការិយាល័យរដ្ឋាភិបាល ។ល។ សម្រាប់ជនរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។

២១. លើកកម្ពស់ជីវភាពរស់នៅ, ផ្តល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ផ្ទះសម្បែង, ហិរញ្ញវត្ថុ និងបច្ចេកវិទ្យាពិសេសសម្រាប់ស្ត្រី។